# បច្ចេកវិទ្យា និងការអប់រំឆ្លាតវៃនៅកម្ពុជា

បច្ចេកវិទ្យាកំពុងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងគ្រប់វិស័យសេដ្ឋកិច្ចសង្គមសំខាន់ៗ ក្នុងនោះបច្ចេកវិទ្យាក៏បាននឹងកំពុងដើរតួយ៉ាងសកម្មផងដែរក្នុងការធ្វើទំនើបកម្មវិស័យអប់រំ។ ជាងនេះទៅទៀត ខណៈពេលដែលវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ បានបង្ខំឲ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលនៅស្ទើរទូទាំងពិភពលោកត្រូវបិទទ្វារ វត្តមានបច្ចេកវិទ្យាបានបង្ហាញកាន់តែច្បាស់អំពីសារៈសំខាន់របស់ខ្លួនក្នុងការផ្តល់ជាដំណោះស្រាយសម្រាប់ធានាបាននូវនិរន្តរភាពក្នុងការបណ្តុះបណ្តាល។ ដោយឡែកសម្រាប់អត្ថបទស្រាវជ្រាវរបស់យើងនាពេលនេះ គឺផ្តោតសំខាន់លើទំនាក់ទំនងរវាងបច្ចេកវិទ្យា និងវិស័យអប់រំវៃឆ្លាតនៅកម្ពុជាទាំងក្នុងនិងក្រោយបរិបទនៃវិបត្តិជំងឺឆ្លងកូវីដ-១៩។

## I.ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំពោះវិស័យអប់រំ

នារយៈកាលចុងក្រោយនេះវិបត្តិជំងឺកូវីដ-១៩ បានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យអប់រំដែលបណ្តាលឲ្យគ្រឹះស្ថានអប់រំនៅតាមបណ្តាប្រទេសនានានៅទូទាំងសកលលោកផ្អាកការអប់រំជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ។យ៉ាងណាមិញបើក្រឡេកមើលអំពីស្ថានភាពនាពេលបច្ចុប្បន្ន ការរីករាលដាលនៃជំងឺកូវីដ-១៩ហាក់មានការធូរស្បើយជាងមុន ដែលអនុញ្ញាតឲ្យប្រទេសមួយចំនួននៅជុំវិញពិភពលោក ចាប់ផ្តើមបើកដំណើរការគ្រឹះស្ថានអប់រំទាំងគ្រឹះស្ថានអប់រំសាធារណៈនិងគ្រឹះស្ថានអប់រំឯកជនឡើងវិញជាបណ្តើរៗហើយ។ យោងតាមទិន្នន័យរបស់អង្គការ UNESCO គិតត្រឹមខែតុលាឆ្នាំ២០២០ការរីករាលដាលនៃជំងឺកូវីដ-១៩ បានផ្តល់ផលប៉ះពាល់ដល់អ្នកសិក្សាប្រមាណជាង៥៧៧លាននាក់នៅពាសពេញពិភពលោក។ ជាមួយគ្នានេះនៅក្នុងអំឡុងពេលនៃការផ្អាកការអប់រំរាជរដ្ឋាភិបាលនៅបណ្តាប្រទេសនានាបានប្រើប្រាស់ការអប់រំពីចម្ងាយដែលក្នុងនោះ២៥%នៃប្រទេសដែលមានប្រាក់ចំណូលទាបបានប្រើប្រាស់ទូរទស្សន៍និងវិទ្យុជាមធ្យោបាយក្នុងការផ្តល់ការអប់រំ ខណៈជិត៩០%នៃប្រទេសដែលមានប្រាក់ចំណូលខ្ពស់បានប្រើប្រាស់ការអប់រំតាមបណ្តាញអ៊ីនធើណែត។ ជាមួយគ្នានេះដែរ ជាង៧០%នៃប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់បានផ្តល់នូវការសិក្សាពីចម្ងាយដោយប្រើប្រាស់ការរួមបញ្ចូលគ្នានៃការអប់រំតាមបណ្តាញអ៊ីនធើណែត និងការចាក់ផ្សាយតាមទូរទស្សន៍ខណៈជាងពាក់កណ្តាលនៃបណ្តាប្រទេសដែលមានប្រាក់ចំណូលទាបបានផ្តល់ការសិក្សាតាមអ៊ីនធើណែត និង/ឬការចាក់ផ្សាយតាមទូរទស្សន៍និងវិទ្យុ។ ចំពោះប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមហាក់ជួបប្រទះនូវកង្វះខាតសម្ភារៈអប់រំតាមបណ្តាញអ៊ីនធើណែត ដោយក្នុងនោះមានតែ ៣៦% នៃសិស្សនិស្សិតប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់បណ្តាញអ៊ីនធើណែតនិងមានឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់។

## ❋ ***វិស័យអប់រំកម្ពុជា***

ដោយឡែក ចំពោះវិស័យអប់រំនៅកម្ពុជាក៏មិនខុសពីបណ្តាប្រទេសនានានៅលើសកលលោកនោះទេ ដែលត្រូវបានគេមើលឃើញថាមានការបង្អាក់ការផ្តល់សេវាកម្មអប់រំជាបណ្តោះអាសន្ន។ គិតត្រឹមបច្ចុប្បន្ននេះ ការបើកគ្រឹះស្ថានអប់រំឡើងវិញនៅកម្ពុជាបានឈានមកដល់ដំណាក់កាលទី៣ហើយ ដោយក្នុងនោះគ្រឹះស្ថានអប់រំសាធារណៈ និងគ្រឹះស្ថានអប់រំឯកជនមួយចំនួនត្រូវបានក្រសួងអប់រំ យុវជន និងកីឡាអនុញ្ញាតឲ្យបើកដំណើរការឡើងវិញ ប៉ុន្តែត្រូវអនុវត្តន៍ទៅតាមគោលការណ៍ និងវិធានសុវត្ថិភាពឱ្យបានហ្មត់ចត់។ យ៉ាងណាមិញនៅក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ការបិទគ្រឹះស្ថានអប់រំនៅកម្ពុជាបានផ្តល់ផលប៉ះពាល់ដល់អ្នកសិក្សាចំនួនជាង ៣,៥លាននាក់ដោយក្នុងនោះសិស្សស្រីមានចំនួនជាង១,៦លាននាក់ នេះបើយោងតាមទិន្នន័យរបស់អង្គការ UNESCO។ នៅកម្ពុជាគេសង្កេតឃើញថា នៅក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ ក្រសួងអប់រំបានដាក់ចេញនូវការបង្រៀនពីចម្ងាយដោយប្រើប្រាស់ការរួមបញ្ចូលគ្នានៃការបង្រៀនតាមបណ្តាញអ៊ីនធើណែតនិងការចាក់ផ្សាយតាមទូរទស្សន៍ ដែលវិធីសាស្រ្តទាំងពីរនេះបានចូលរួមចំណែកជួយដល់ការសិក្សារបស់សិស្សានុសិស្សបានមួយផ្នែក។ជាងនេះទៅទៀត សិស្សានុសិស្សដែលរស់នៅតាមបណ្តាខេត្តដែលខ្វះខាតសំភារៈ ឬឧបករណ៍ជំនួយដូចជា ប្រព័ន្ធអ៊ីនធើណែតអាចទទួលបានការអប់រំតាមរយៈការចាក់ផ្សាយតាមទូរទស្សន៍ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដូចជាចូលរួមរក្សាគម្លាតសង្គម (Social Distancing)ផងដែរ។ យោងតាម ការស្ទង់មតិរបស់មជ្ឈមណ្ឌលកម្ពុជា៤.0ដែលបានសិក្សាអំពីផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ទៅលើវិស័យអប់រំកាលពីខែមេសា ឆ្នាំ២០២០ កន្លងទៅសិស្សនិស្សិតដែលបានចូលរួមឆ្លើយស្ទើរតែទាំងអស់បានបង្ហាញការយល់ស្របដូចៗគ្នាថាការសិក្សារបស់ពួកគេបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការរីករាលដាលជំងឺកូវីដ-១៩ខណៈគ្រឹះស្ថានអប់រំរបស់ពួកគេបានបិទ និង/ឬផ្អាកដំណើរការ។




ផលប៉ះពាល់លើការសិក្សាជាទូទៅ

ក្នុងនោះ មានសិស្សប្រមាណ **៦៦%** មិនបានទទួលបានការអប់រំពីចម្ងាយនោះទេដោយសារគ្រឹះស្ថានអប់រំរបស់ពួកគេពុំទាន់បានរៀបចំប្រព័ន្ធសិក្សាពីចម្ងាយបានរួចរាល់។ ដោយឡែក មានសិស្សប្រមាណតែ៣៤% ប៉ុណ្ណោះដែលបានបញ្ជាក់ថាពួកគេបានទទួលការអប់រំពីចម្ងាយបើទោះបីជាគ្រឹះស្ថានអប់រំរបស់ពួកគេបានផ្អាកដំណើរការក៏ដោយ។




ការយល់ឃើញរបស់សិស្សនិស្សិតចំពោះការសិក្សាកំឡុងពេលរីករាលដាលជំងឺកូវីដ-១៩

ផ្ទុយទៅវិញ ចំពោះការសិក្សាតាមបណ្ដាញអ៊ីនធឺណែត បើទោះបីជាបច្ចេកវិទ្យាបានជួយដល់ការសិក្សាបានមួយផ្នែកនិងជាបណ្ដោះអាសន្នក៏ដោយ ក្នុងនោះមានសិស្សប្រមាណតែ១៦%ប៉ុណ្ណោះដែលបានយល់ស្របអំពីប្រសិទ្ធភាពខ្ពស់ក្នុងការសិក្សាពីចម្ងាយខណៈសិស្សច្រើនជាង៦៩% ផ្សេងទៀតបានបង្ហាញការយល់ឃើញថាការសិក្សារបស់ពួកគេហាក់មានការធ្លាក់ចុះបើធៀបទៅនឹងការសិក្សានៅតាមគ្រឹះស្ថានសិក្សាដោយផ្ទាល់។ក្នុងន័យនេះ គេសង្កេតឃើញថា មូលហេតុចម្បងគឺបណ្ដាលមកពីអ្នកប្រើប្រាស់ពុំមានចំណេះដឹងគ្រប់គ្រាន់លើផ្នែកបច្ចេកវិទ្យាមិនទាន់ចេះប្រើប្រាស់បច្ចេកវិទ្យា មិនទាន់មានភាពស៊ាំទៅនឹងការអប់រំពីចម្ងាយ និងនៅមានកង្វះខាតហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាឧបករណ៍ប្រើប្រាស់សម្រាប់ការសិក្សាពីចម្ងាយដែលជាហេតុបណ្ដាលឲ្យការសិក្សារបស់ពួកគេហាក់ពុំសូវយល់ និងមានការពិបាកក្នុងការសួរនាំ និងសុំការពន្យល់ពីលោកគ្រូ/អ្នកគ្រូនិងមិត្តភក្តិ។

ទស្សនៈយល់ឃើញរបស់សិស្ស-និស្សិតចំពោះ "ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការសិក្សាពីចម្ងាយ"




## II.គ្រូបង្រៀនឆ្លាតវៃនៅក្នុងយុគសម័យឌីជីថល

ខណៈពេលដែលបច្ចេកវិទ្យាកំពុងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិស័យសេដ្ឋកិច្ចសង្គមសំខាន់ៗ ក្នុងនោះបច្ចេកវិទ្យាក៏បាននឹងកំពុងដើរតួយ៉ាងសកម្មផងដែរក្នុងការធ្វើទំនើបកម្មវិស័យអប់រំ។ យ៉ាងណាមិញ គ្រូបង្រៀនគឺជាកម្លាំងចលករមួយដ៏សំខាន់ក្នុងការរុញដោលការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យអប់រំក៏ដូចជាការឆ្ពោះទៅរកការអប់រំឌីជីថលនៅកម្ពុជា។ជាក់ស្ដែងនាឱកាសទិវាគ្រូបង្រៀន ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាបានលើកឡើងអំពីកោសិកាស្នូលនៃប្រព័ន្ធអប់រំ ដែលចែកចេញជា ៤ កត្តាធំៗ រួមមាន៖ នាយក, គ្រូបង្រៀន, សិស្ស និងមាតាបិតាក៏ដូចជាសហគមន៍។ ក្នុងនោះផងដែរនៅក្នុងយុគសម័យឌីជីថលគ្រូបង្រៀនត្រូវមានលក្ខណៈសម្បត្តិ**៥ យ៉ាងដូចជា៖**

**១). ចំណេះដឹងរឹងមាំ និងទូលំទូលាយ (រួមទាំងភាសាបរទេស)៖** ដោយក្នុងនោះគ្រូបង្រៀនត្រូវមានចំណេះដឹងអំពីសិស្ស ចំណេះដឹងអំពីខ្លឹមសារមេរៀន និងចំណេះដឹងអំពីរបៀបរៀនរបស់សិស្ស។

**២). បំណិនវិជ្ជាជីវៈ (ការស្រាវជ្រាវ)៖** ការគ្រប់គ្រងបរិស្ថានសិក្សានិងតាមដានលទ្ធផលសិក្សា,អនុវត្តន៍វិធីសាស្ត្របង្រៀនសម្បូរបែបទាំងទ្រឹស្តីអាកប្បកិរិយា ទ្រឹស្តីសតិបញ្ញា និងទ្រឹស្តីបង្រៀនតាមបែបស្ថាបនា។

**៣).ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីមានបទពិសោធន៍វិជ្ជាជីវៈ៖** គ្រូបង្រៀនត្រូវផ្សារភ្ជាប់ការអភិវឌ្ឍវិជ្ជាជីវៈទៅនឹងគន្លងអាជីពនិងត្រូវចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីកែលម្អការសិក្សារបស់សិស្សបង្កើតវប្បធម៌កិច្ចសហការរបស់គ្រូនិងផ្តោតលើលទ្ធផលការសិក្សារបស់សិស្ស។

**៤). សីលធម៌វិជ្ជាជីវៈ៖** ត្រូវយកចិត្តទុកដាក់និងថែរក្សាសិស្ស, បង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌និងមានទំនាក់ទំនងដោយសុខដុមជាមួយសិស្សនិងសហគមន៍, និងមានភាពយុត្តិធម៌និងតម្លាភាពជាមួយសិស្ស សហសេវិកនិងសមាជិកផ្សេងៗរបស់សហគមន៍។

**៥).បំណិនឌីជីថល (បច្ចេកវិទ្យា)៖** ត្រូវមានចំណេះដឹងចិត្តគរុកោសល្យ និងមុខវិជ្ជា, ចំណេះដឹងបច្ចេកវិទ្យា និងមុខវិជ្ជា, និងចំណេះដឹងស្តីពីការប្រើប្រាសបច្ចេកវិទ្យាក្នុងការបង្រៀន។

យ៉ាងណាមិញ ប្រព័ន្ធគរុកោសល្យនៃសាលារៀនឆ្លាតវៃត្រូវមានសមាសភាគសំខាន់ៗចំនួន៧រួមមាន អភិបាលកិច្ច,វិធីសាស្ត្របង្រៀនថ្មី, បច្ចេកវិទ្យាប្រព័ន្ធប្រឹក្សាគរុកោសល្យនៅសាលារៀនឆ្លាតវៃ, ការរៀបចំថ្នាក់រៀន និងសំភារៈឧបទ្ទេស, សហគមន៍សិក្សាវិជ្ជាជីវៈ និងបណ្ណាល័យសតវត្សទី២១។

### III.បច្ចេកវិទ្យាឌីជីថលដែលមានសក្តានុពលសម្រាប់វិស័យអប់រំនៅកម្ពុជា

ដើម្បីឈានទៅរកការអប់រំឆ្លាតវៃវិស័យអប់រំមានភារកិច្ចពីរគឺទទួលយកនូវបច្ចេកវិទ្យាថ្មីដើម្បីកែលម្អប្រសិទ្ធភាពរបស់ខ្លួន និងបង្កើតធនធានមនុស្សដែលអាចប្រើប្រាស់ឧបករណ៍ថ្មីៗដែលមានស្រាប់ និង/ឬបង្កើតបច្ចេកវិទ្យាថ្មីៗ សម្រាប់ជាប្រយោជន៍ដល់វិស័យអប់រំខ្លួនឯងផ្ទាល់ និងវិស័យដទៃទៀតផងដែរ។ ជាក់ស្តែង បច្ចេកវិទ្យាថ្មីៗបាននឹងកំពុងជួយសម្រួលដល់ការសិក្សារបស់សិស្ស និស្សិត តាមរយៈការផ្តល់លទ្ធភាពស្វែងយល់អំពីចំណេះដឹងនិងការស្រាវជ្រាវថ្មីៗតាមប្រព័ន្ធអនឡាញ ខណៈពួកគេអាចទទួលបាននូវឯកសារជាអត្ថបទអេឡិចត្រូនិកឬជាសំលេងឬជាវីដេអូដោយមិនគិតថ្លៃ ឬដោយគ្រាន់តែចំណាយតិចតួចបំផុត។

ខាងក្រោមនេះ គឺជាសម្រង់បច្ចេកវិទ្យាឌីជីថលមួយចំនួនដែលបាននឹងកំពុងត្រូវបានប្រើប្រាស់នៅក្នុងវិស័យអប់រំនៅតាមបណ្តាប្រទេសមួយចំនួននៅជុំវិញពិភពលោក និងមានសក្តានុពលសម្រាប់វិស័យអប់រំកម្ពុជា៖

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១ | បញ្ញាសិប្បនិម្មិត (Artificial Intelligence) | បច្ចេកវិទ្យា AIត្រូវបានប្រើប្រាស់នៅតាមបណ្តាប្រទេសជឿនលឿនជាច្រើន។ ប្រទេសអូស្ត្រាលី ប្រើប្រាស់ AIសម្រាប់ជាជំនួយក្នុងការឆ្លើយសំណួរនិងជួយដោះស្រាយបញ្ហារបស់សិស្សនិស្សិត |  |
| ២ | Chatbot | បណ្តាប្រទេសមួយចំនួនដូចជាប្រទេសចិន ជប៉ុន  កូរ៉េខាងត្បូង និងហ្វីលីពីនបាននឹងកំពុងប្រើប្រាស់ Chatbot ដោយមានបំពាក់ភាសាច្រើនប្រភេទសម្រាប់ជួយដោះស្រាយបញ្ហានៅក្នុងការសិក្សារបស់សិស្សនិស្សិត ដូចជាជួយដោះស្រាយលំហាត់ កិច្ចការផ្ទះ និងជួយស្រាយចំងល់ផ្សេងៗ |  |
| ៣ | AR & VR & Mixed Reality | បច្ចេកវិទ្យាទាំងនេះត្រូវបានគេប្រើប្រាស់សម្រាប់ជួយសម្រួលដល់សិស្សនិស្សិតដែលអនុញ្ញាតឲ្យពួកគេអាចសិក្សាពីចម្ងាយនិងអាចមើលឃើញរូបភាពជាក់ស្តែងដោយផ្សារភ្ជាប់ការសិក្សារបស់ពួកគេទៅនឹងឧទាហរណ៍ជាក់ស្តែង។ក្នុងនោះគេឃើញមានប្រទេសចិននិងប្រទេសមីយ៉ាន់ម៉ាបាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យាទាំងនេះសម្រាប់ការបង្រៀនមុខវិជ្ជាភូមិវិទ្យានិងមុខវិជ្ជាផ្សេងទៀត |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ៤ | កាមេរ៉ាចាប់យកសកម្មភាពក្នុងថ្នាក់រៀន (Lecture Recording Cameras) | បច្ចេកវិទ្យាកាមេរ៉ាវៃឆ្លាតបំពាក់ក្នុងថ្នាក់រៀន ត្រូវបានគេឃើញមាននៅប្រទេសតៃវ៉ាន់ ដែលបច្ចេកវិទ្យានេះអនុញ្ញាតឲ្យសិស្សអាចរៀនពីចម្ងាយ មើលវីដេអូនៅក្នុងថ្នាក់រៀនឡើងវិញ ទាំងពេលដែលពួកគេបានឬមិនបានមករៀន | <br> |
| ៥ | Speech to Text | ឧបករណ៍កត់ត្រារាល់ការសន្ទនានៅក្នុងថ្នាក់ ដោយបម្លែងពីសំឡេងទៅជាអត្ថបទ ដែលអាចជាជំនួយ និង/ឬជំនួសឲ្យការកត់ត្រាដោយផ្ទាល់ដៃ។ ឧបករណ៍នេះត្រូវបានគេឃើញមានវត្តមាននៅបណ្តាប្រទេសអភិវឌ្ឍមួយចំនួន រួមមានសហរដ្ឋអាមេរិកជាដើម |  |
| ៦ | ក្តារខៀនវៃឆ្លាត (Smart Board) | ប្រទេសចិននិងឥណ្ឌាត្រូវបានគេឃើញមានការប្រើប្រាស់ឧបករណ៍នេះដោយមានភ្ជាប់ជាមួយឧបករណ៍បញ្ចាំងរូបភាពនិងកុំព្យូទ័រ ដែលអាចជួយសម្រួលនិងផ្តល់ភាពងាយស្រួលដល់ការសិក្សា និងការធ្វើលំហាត់ផ្សេងៗ ខណៈសិស្ស និងគ្រូអាចបញ្ជា ឬចុចលើក្តារខៀនបានដោយផ្ទាល់ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ៧ | តុវៃឆ្លាត (Smart Table) | ឧបករណ៍នេះត្រូវបានគេឃើញមានវត្តមាននៅបណ្ដាប្រទេសជាច្រើនរួចមកហើយ រួមទាំងសហរដ្ឋអាមេរិក និងប្រទេសចិនដែលវាអាចជួយសម្រួលដល់ការធ្វើការងារជាក្រុម ដោយសិស្សអាចជួយគ្នាដោះស្រាយលំហាត់ ឬសំណួរផ្សេងៗ ក្នុងពេលតែមួយ |  |
| ៨ | Paperless Textbooks | សៀវភៅឌីជីថល(Paperless)ជំនួសឲ្យសៀវភៅក្រដាស ដែលសៀវភៅឌីជីថលនេះអនុញ្ញាតឲ្យសិស្សអានអត្ថបទជាច្រើន នៅក្នុងឧបករណ៍តែមួយ។ ឧបករណ៍នេះត្រូវបានគេឃើញមាននៅប្រទេសជាច្រើនរួចទៅហើយរួមទាំងកម្ពុជាផងដែរ |  |
| ៩ | កុំព្យូទ័រ,ថេបប្លេត និងទូរស័ព្ទ (Computer, tablets Mobile Devices) | ឧបករណ៍ដ៏សំខាន់សម្រាប់គ្រូនិងសិស្ស សម្រាប់បង្រៀន សិក្សា និងស្រាវជ្រាវ ដែលផ្ដល់ភាពងាយស្រួលក្នុងការយកតាមខ្លួន។ វាត្រូវបានប្រើប្រាស់នៅស្ទើរតែគ្រប់ប្រទេសទៅហើយក្នុងនោះក៏មានកម្ពុជាផងដែរ |  |
| ១០ | E-Portfolios | អនុញ្ញាតឲ្យគ្រូអាចបង្កើតកាតាឡុកអេឡិចត្រូនិកមួយ សម្រាប់តាមដានកិច្ចការរបស់សិស្សនិស្សិត ដែលជាធម្មតាត្រូវបានតភ្ជាប់ជាមួយបណ្ដាញអ៊ីនធើណែត។ ប្រទេសជាច្រើនក្នុងនោះមានប្រទេសជប៉ុន ប្រើប្រាស់បច្ចេកវិទ្យានេះ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១១ | Big Data | ប្រទេសមួយចំនួនដូចជា ប្រទេសចិន និងឥណ្ឌា ប្រើប្រាស់ Big Data សម្រាប់ជាជំនួយដល់គ្រូបង្រៀន ក្នុងការស្វែងយល់ បន្ថែមអំពីសិស្ស ដែលអាចផ្តល់ព័ត៌មានអំពីរបៀបដែលសិស្សរៀន និងស្វែងយល់អំពីភាពខ្លាំង និងភាពខ្សោយរបស់សិស្ស |   |
| ១២ | បណ្តាញសង្គម (Social Networking) | បណ្តាញសង្គមមានទម្រង់ជាវេបសាយ និងកម្មវិធី(Application)ប្រើប្រាស់ ដើម្បីបង្កើតអន្តរកម្មរវាងគ្រូនិងសិស្ស ដែលគ្រូអាចបង្កើតលំហាត់ ហើយសិស្សអាចដោះស្រាយបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដោយគ្រាន់តែភ្ជាប់បណ្តាញអ៊ីនធើណែត។ កម្ពុជាក៏បាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យានេះផងដែរ |   |
| ១៣ | Learning Analytics | ហុងកុងត្រូវបានគេឃើញមានប្រើប្រាស់បច្ចេកវិទ្យានេះ នៅក្នុងការប្រមូលវិភាគ និងរាយការណ៍ទិន្នន័យ ដែលវាអាចសម្រួលដល់ការតាមដានការសិក្សារបស់សិស្ស និងកែសម្រួលនូវកង្វះខាតផ្សេងៗ |   |
| ១៤ | Gamification | នៅប្រទេសជប៉ុន កម្មវិធីនេះត្រូវបានប្រើប្រាស់សម្រាប់ឲ្យសិស្សផ្តោតអារម្មណ៍ និងមានអារម្មណ៍រីករាយក្នុងការស្រាវជ្រាវ ក៏ដូចជា ដោះស្រាយបញ្ហា តាមរយៈ ការប្រកួតប្រជែងគ្នានៅក្នុងបរិបទសិក្សា |   |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១៥ | Podcasting | ឧបករណ៍សម្រាប់ទាញយកឯកសារជាសំឡេងមកស្តាប់។ ប្រទេសជប៉ុន ប្រទេសចិន និងបណ្តាប្រទេសមួយចំនួន ផ្សេងទៀតប្រើប្រាស់ឧបករណ៍នេះកម្ពុជាក៏បាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យានេះផងដែរ |  |
| ១៦ | Cloud Computing | ប្រទេសភាគច្រើន និងរួមទាំងកម្ពុជាផងដែរ ប្រើប្រាស់ Cloud Computing សម្រាប់រក្សាទុកឯកសារជាទម្រង់ឌីជីថល ដែលអនុញ្ញាតឲ្យសិស្សអាចចូលទៅមើលឯកសារទាំងអស់បាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដោយគ្រាន់តែមានភ្ជាប់បណ្តាញអ៊ីនធើណែត |   |
| ១៧ | LCD Projectors | ឧបករណ៍បញ្ជូនរូបភាពពីកុំព្យូទ័រទៅកាន់Projectorដើម្បីបញ្ចាំងរូបភាពឲ្យមានទម្រង់ធំនៅលើក្តារខៀន ឬជញ្ជាំង។ ឧបករណ៍នេះមានភាពពេញនិយមនៅបណ្តាប្រទេសជាច្រើនរួមទាំងកម្ពុជាផងដែរ |  |

បច្ចេកវិទ្យាឌីជីថលទាំងអស់ដែលបានរៀបរាប់ខាងលើ គឺសុទ្ធសឹងតែមានសក្តានុពលសម្រាប់វិស័យអប់រំនៅកម្ពុជាក្នុងការយកមកប្រើប្រាស់។ ដោយឡែកក្នុងនោះក៏មានបច្ចេកវិទ្យាមួយចំនួនដែលចាំបាច់សម្រាប់កម្ពុជាយកមកអនុវត្តន៍នៅក្នុងដំណាក់កាលចាប់ផ្តើមនេះ។ ក្រៅពីនេះបច្ចេកវិទ្យាដទៃទៀតក៏មានសក្តានុពលផងដែរសម្រាប់កម្ពុជាយកមកអនុវត្តន៍នៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀតឬដំណាក់កាលក្រោយៗទៀត។ ដោយឡែក ក្នុងចំណោមបច្ចេកវិទ្យាឌីជីថលទាំងនេះបច្ចេកវិទ្យាខ្លះ កម្ពុជាអាចរកធនធានពីខាងក្នុងប្រទេសបាន ខណៈបច្ចេកវិទ្យាខ្លះទៀតតម្រូវឲ្យកម្ពុជារកធនធានឬនាំចូលពីខាងក្រៅប្រទេស។

## IV. ជំនាញឌីជីថលដែលមានសក្តានុពលសម្រាប់វិស័យអប់រំនៅកម្ពុជា

ជំនាញឌីជីថលគឺជាភាពប៉ិនប្រសប់និងស្ទាត់ជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងវិស័យពាក់ព័ន្ធផ្សេងៗ។យ៉ាងណាមិញដើម្បីឆ្ពោះទៅសម្រេចបាននូវការអប់រំឆ្លាតវៃ ជំនាញនេះគឺពិតជាមានភាពចាំបាច់ និងមិនអាចខ្វះបាន។ផ្ទុយទៅវិញជំនាញឌីជីថលចាំបាច់ត្រូវដើរទន្ទឹមគ្នានឹងបច្ចេកវិទ្យាឌីជីថលដែលធានាឲ្យបានថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលមានស្រាប់ក៏ដូចជាឈានទៅរកការបង្កើតបច្ចេកវិទ្យាឌីជីថលដោយខ្លួនឯង។ ជាមួយគ្នានេះដែរ ជំនាញឌីជីថលត្រូវបានបែងចែកជា៣កម្រិតផ្សេងៗគ្នា រួមមាន កម្រិតមូលដ្ឋាន កម្រិតមធ្យម និង កម្រិតខ្ពស់ ដែលបែងចែកទៅតាមកម្រិតការយល់ដឹងនិងជំនាញផ្សេងៗគ្នា៖

### ក. កម្រិតមូលដ្ឋាន (Basic Digital Skills)៖

ជំនាញមូលដ្ឋានសម្រាប់អ្នកប្រើប្រាស់ទូទៅនៅក្នុងវិស័យអប់រំរួមមានលោកគ្រូ-អ្នកគ្រូ មាតាបិតា-អាណាព្យាបាលសិស្សនិស្សិត និងសិស្សនិស្សិតជាដើម។

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
|---|---|---|
| ១ | អក្ខរកម្មឌីជីថល (Digital Literacy) | ចំណេះដឹងមូលដ្ឋានអំពីការប្រើប្រាស់បច្ចេកវិទ្យាទូទៅនិងបច្ចេកវិទ្យាថ្មីៗ |
| ២ | បណ្តាញសង្គម | អាចប្រើប្រាស់បណ្តាញសង្គម ប្រកបដោយការទទួលខុសត្រូវនិងជំនាញក្នុងការភ្ជាប់ទំនាក់ទំនងគ្នា |
| ៣ | អ៊ីម៉ែល (Email) | អាចប្រើប្រាស់ Email ក្នុងការសន្ទនាផ្លូវការដែលអនុញ្ញាតឲ្យធ្វើការផ្ញើរសារជារូបភាព វីដេអូនិងឯកសារផ្សេងៗ |
| ៤ | Office Program | អាចប្រើប្រាស់កម្មវិធី Microsoft Office សំខាន់ៗមួយចំនួន ដូចជា Microsoft Word, Exel, Powerpoint, Outlook ជាដើម |

| | | |
|---|---|---|
| ៥ | សេវាកម្មទូទាត់តាមអនឡាញ (Online Payment Service) | អាចប្រើប្រាស់សេវាកម្មទូទាត់ហិរញ្ញវត្ថុតាមបណ្ដាញអនឡាញប្រកបដោយសុវត្ថិភាព។ ឧទាហរណ៍ E-learning ខ្លះតម្រូវឲ្យមានការបង់ប្រាក់តាមបណ្ដាញអនឡាញ |
| ៦ | ម៉ាស៊ីនស្វែងរក (Search Engine) | ចំណេះដឹងក្នុងការស្វែងរកព័ត៌មាន ដោយសុក្រឹតត្រឹមត្រូវ និងទុកចិត្តបាន នៅតាមប្រព័ន្ធអ៊ីនធើណែត |

***ខ. កម្រិតមធ្យម ( Mid-Level Digital Skills)៖*** *សម្រាប់អ្នកដែលមានជំនាញឌីជីថលកម្រិតមធ្យមដែលអាចប្រើប្រាស់មុខងារនៃបច្ចេកវិទ្យាឌីជីថលដែលមានភាពស្មុគស្មាញមួយចំនួននិងមុខងារពិសេសៗមួយចំនួនទៀត។ភាគីពាក់ព័ន្ធទាំងនោះអាចជាលោកគ្រូ-អ្នកគ្រូ សិស្ស-និស្សិតបុគ្គលិកបម្រើការនៅក្នុងវិស័យអប់រំ-ល-។*

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
|---|---|---|
| ១ | ការថត និងកែសម្រួលសំឡេង (Record and edit audio clips) | ជំនាញថត និងកាត់តសំឡេងជាមួយកម្មវិធីកុំព្យូទ័រ និងទូរស័ព្ទដែលបង្កភាពងាយស្រួល ក្នុងការបង្រៀន និងរៀនពីចម្ងាយ។ កម្មវិធីមួយចំនួនដូចជា SoundCloud, Audioboom, Vocaroo |
| ២ | ការបង្កើតបទបង្ហាញ (Create Engaging Presentation) | ជំនាញក្នុងការបង្កើត និងប្រើប្រាស់កម្មវិធីធ្វើបទបង្ហាញដូចជា Google Slide, Haiku Deck, Prezi, Zoho Presentationដែលកម្មវិធីទាំងនេះផ្ដល់ភាពងាយស្រួលក្នុងការចែករំលែកនៅលើប្រព័ន្ធអ៊ីនធើណែតក៏ដូចជាការកែសម្រួលខ្លឹមសារផ្សេងៗរួមគ្នាក្នុងពេលតែមួយ |
| ៣ | ការបង្កើតលំហាត់ ឬ សំណួរ (Create Quizzes) | ជំនាញក្នុងការបង្កើតលំហាត់តាមប្រព័ន្ធអ៊ីនធើណែតដូចជា Kahoot, Testmoz, Quizalize, Factile, Riddle, Quiz Bean។ ការបង្កើត Quizzesតាមប្រពន្ធអ៊ីនធើណែតផ្ដល់ភាពងាយស្រួលដល់គ្របង្រៀនក្នុងការតាមដានពីពេលវេលា ដែលសិស្សបានបំពេញកិច្ចការ |

| | | |
|---|---|---|
| ៤ | Digital Portfolios | ជំនាញបង្កើតទំព័រ Portfolios ខ្លួនឯងនៅតាមប្រព័ន្ធអ៊ីនធើណែត។ វាផ្តល់ងាយស្រួលដល់គ្រូបង្រៀនក្នុងការចែករំលែកឯកសារទៅកាន់សិស្ស-និស្សិត។ Portfolios ល្បីៗមានដូចជា Google Site, SeeSaw, Pathbrith |
| ៥ | ការគ្រប់គ្រងទិន្នន័យ (Data Management) | ការគ្រប់គ្រងទិន្នន័យសិស្ស-និស្សិត។ វាអនុញ្ញាតឲ្យគ្រូអាចយល់អំពីសិស្ស- និស្សិតកាន់តែច្បាស់ និងអាចដឹងពីដំណើរការសិក្សារបស់ពួកគេប្រកបដោយប្រសិទ្ធភាព |
| ៦ | ព័ត៌មានវិទ្យា (Information Technology) | ចំណេះដឹងផ្នែកព័ត៌មានវិទ្យាចាំបាច់មួយចំនួនដែលពាក់ព័ន្ធ |
| ៧ | ជំនាញឌីសាញ (Designing) | ជំនាញក្នុងការឌីសាញរូបភាពឬឯកសារផ្សេងៗ |

***គ. កម្រិតខ្ពស់ (Advanced Digital Skills) ៖*** *ជំនាញកម្រិតខ្ពស់សម្រាប់ភាគីពាក់ព័ន្ធដែលមានចំណេះដឹង និងជំនាញផ្នែកបច្ចេកវិទ្យាកម្រិតខ្ពស់ ដែលអាចប្រើប្រាស់កម្មវិធីដែលមានភាពស្មុគស្មាញ ក៏ដូចជាបង្កើតកម្មវិធីថ្មីមួយចំនួនបានដោយខ្លួនឯង ដែលអ្នកទាំងនោះអាចជាបុគ្គលិកជំនាញផ្នែកព័ត៌មានវិទ្យាផ្នែកសរសេរកូដកម្មវិធីផ្នែកវិភាគទិន្នន័យ និងផ្នែកពាក់ព័ន្ធមួយចំនួនទៀត។*

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
|---|---|---|
| ១ | ការសរសេរកូដកម្មវិធី (Coding) | អាចសរសេរកូដកម្មវិធីគ្រប់គ្រង ឬ បង្កើតកម្មវិធីថ្មីៗ |
| ២ | Software Programming | ការបង្កើតកម្មវិធីឌីជីថលដែលចាំបាច់ |
| ៣ | Data Science & Data Analytics | ការវិភាគ និងបកស្រាយទិន្នន័យ |
| ៤ | ការច្នៃប្រឌិតឌីជីថល (Digital Creativity) | អាចប្រើឧបករណ៍ឌីជីថល ដើម្បីបំពេញការងារដែលមានភាពស្មុគស្មាញ សម្រាប់វិភាគ និងស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត |

ជំនាញឌីជីថលទាំងអស់ដែលបានរៀបរាប់ខាងលើគួរត្រូវបានយកមកបណ្តុះបណ្តាល និងបញ្ជ្រាបការយល់ដឹងដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងបុគ្គលិក គ្រូបង្រៀន សិស្សនិស្សិត និងប្រជាពលរដ្ឋ។ ដោយឡែក ចំពោះជំនាញកម្រិតខ្ពស់គឺសម្រាប់ផ្តល់ការបណ្តុះបណ្តាលចំពោះបុគ្គលិកជំនាញដែលធ្វើការពាក់ព័ន្ធនឹងការអប់រំវៃឆ្លាត។ ជារួម សម្រាប់ដំណាក់កាលក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ យើងគួរបន្តជំរុញការអភិវឌ្ឍធនធានមនុស្សបន្ថែមទៀតដោយរួមបញ្ចូលទាំងចំណេះ និងជំនាញ ក៏ដូចជាសមត្ថភាពផ្នែកបច្ចេកវិទ្យាកម្រិតមូលដ្ឋានដើម្បីអាចប្រើប្រាស់ជាជំនួយក្នុងការពន្លឿនការអភិវឌ្ឍវិស័យអប់រំវៃឆ្លាតនៅកម្ពុជា។ ជាមួយគ្នានេះផងដែរ បណ្តាញទូរគមនាគមន៍ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាមូលដ្ឋានផ្សេងទៀត ដូចជាបណ្តាញអគ្គិសនី អ៊ីនធើណែតជាដើមក៏សុទ្ធតែមានសារៈសំខាន់សម្រាប់ជំរុញការអភិវឌ្ឍវិស័យអប់រំវៃឆ្លាតនៅកម្ពុជាឱ្យទទួលបានជោគជ័យនាពេលខាងមុខ។

## ឯកសារយោង


១."គ្រូបង្រៀនឆ្លាតវៃ ដើម្បីការអប់រំឌីជីថលនៅកម្ពុជា",បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ០៥ តុលា ២០២០ https://bit.ly/36tAaOV

២. ការស្ទង់មតិរបស់មជ្ឈមណ្ឌលកម្ពុជា ៤.0 ស្តីអំពី "ផលប៉ះពាល់នៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩លើវិស័យទេសចរណ៍ វិស័យអប់រំនិងយុវជន វិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌និងសាសនា" ខែមេសា ឆ្នាំ២០២០

៣. អង្គការ Unesco, ចូលអានថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ https://en.unesco.org/covid19/educationresponse

៤. ក្រសួងអប់រំ យុវជន និងកីឡា, ចូលអានថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ https://www.moeys.gov.kh/index.php/kh/

៥. Kitaboo, ចូលអាន ខែសីហា ឆ្នាំ២០២០ https://kitaboo.com/top-innovations-in-k-12-education/

៦. Cambridge Assessment International Education, ចូលអាន ខែសីហា ឆ្នាំ២០២០ https://www.cambridgeinternational.org/Images/271191-digital-technologies-in-the-classroom.pdf

៧. Digital technology and mobile learning, ចូលអាន ខែកញ្ញា ឆ្នាំ២០២០ https://www.educatorstechnology.com/2012/06/33-digital-skills-every-21st-century.html

៨. Kitaboo, ចូលអាន ខែសីហា ឆ្នាំ២០២០ https://kitaboo.com/trends-in-education-technology/

៩. Techavio Blog, ចូលអាន ខែសីហា ឆ្នាំ២០២០ https://blog.technavio.com/blog/top-10-trends-in-educational-technology

១០. Info Fort, Smart Education Solution, ចូលមើល ខែកញ្ញា ឆ្នាំ២០២០ https://www.youtube.com/watch?v=vT_bRAQw9sc

១១. Keith Krach, 13 of the Latest Trends in Educational Technology, ចូលមើល ខែកញ្ញា ឆ្នាំ២០២០ https://medium.com/@KeithKrach/13-of-the-latest-trends-in-educatioal-technology-e2368e36f7a0


www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

cambodia4point0